**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :០៤.សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

## I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

### ក- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

១- ឆ្នាំ ២០០៦ គឺជាឆ្នាំទីមួយនៃការចាប់ផ្តើមអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ហើយក៏ជាឆ្នាំទីបីនៃការដាក់អោយអនុវត្ត យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ក្នុងគោលបំណងធានាអោយបាននូវកំណើនសេដ្ឋកិច្ចកំរិតខ្ពស់ប្រកបដោយចិរភាព និង សមធម៌ ដែលជាកត្តាគន្លឹះដ៏សំខាន់បំផុតសំរាប់សំរេចបានជោគជ័យនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំនៃការបន្តជំរុញការលើកកំពស់អភិបាលកិច្ចល្អតាមរយៈកម្មវិធីកែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ជាពិសេស ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

២- តាមការប៉ាន់ស្មានចុងក្រោយរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចគិតតាមថ្លៃថេរសំរាប់ឆ្នាំ ២០០៦ សំរេចបាន ១០,៨% ធៀបនឹងការព្យាករណ៍ប្រមាណ ៦,១% នៅដើមឆ្នាំ ។ កំណើននេះ បានមកដោយសារ វិស័យកសិកម្មបានកើនប្រមាណ ៥,៥% ដែលក្នុងនោះ ផលស្រូវបានកើនប្រមាណ ៥,៣% វិស័យឧស្សាហកម្មបានកើនប្រមាណ ១៨,៣% ដែលក្នុងនោះ ផលិតកម្មវាយនភ័ណ្ឌបានកើនប្រមាណ ២០,៤% និង ផលិតកម្មសំណង់បានកើនប្រមាណ ២០% និង វិស័យសេវាកម្មបានកើនប្រមាណ ១០,៣% ដែលក្នុងនោះ សកម្មភាពទេសចរណ៍បានកើនប្រមាណ ១១,៧% ។ គួរកត់សំគាល់ថា នេះគឺជាស្ថានភាពសេដ្ឋកិច្ចដែលកម្ររកបាន គឺកំណើនសេដ្ឋកិច្ចខ្ពស់ អតិផរណាទាបប្រមាណ ៣% ហើយអត្រាប្តូរប្រាក់ក៏មានស្ថេរភាពល្អថែមទៀតគឺស្ថិតនៅក្នុងរង្វង់ប្រមាណ ៤ ១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ទោះជាត្រូវរងឥទ្ធិពលនៃការឡើងថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិក៏ដោយ ។

៣- ក្នុងឆ្នាំ ២០០៧ នេះ តាមការព្យាករណ៍ចុងក្រោយ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានប្រមាណ ៨,៥% ធៀបនឹងការព្យាករណ៍ដើមឆ្នាំត្រឹម ៦,៥% ។ សេណារីយោសុទិដ្ឋិនិយមជាងមុននេះ គឺក្រោយពីសង្កេតឃើញថា ផលិតកម្មវាយនភណ្ឌ និង សកម្មភាពទេសចរណ៍នៅតែបន្តកើនឡើង ហាក់ដូចជាពុំទាន់ទទួលឥទ្ធិពលប្រកួតប្រជែងពីប្រទេសវៀតណាម និង ចិននៅឡើយ ។ ម្យ៉ាងទៀត ផលិតភាពកសិកម្មក៏ត្រូវបាន និង កំពុងបន្តបង្កើនជាបន្តបន្ទាប់ ជាពិសេស តាមរយៈការបង្កើនផ្ទៃដីដាំស្រូវដោយប្រព័ន្ធស្រោចស្រព និង ការបង្កើនទិន្នផលស្រូវ ។ ទន្ទឹមនឹងនេះ ឆ្នាំនេះភ្លៀងធ្លាក់ដើមឆ្នាំ ប្រសិនបើមានភ្លៀងគ្រប់គ្រាន់រហូតដល់ចុងឆ្នាំដោយមិនជួបប្រទះគ្រោះទឹកជំនន់នោះទេ កំណើនវិស័យកសិកម្ម និង កំណើនសេដ្ឋកិច្ចអាចសំរេចបានខ្ពស់ជាងការព្យាករណ៍នេះ ។ ទោះជាយ៉ាងណា តាមសេណារីយ៉ូខាងលើនេះ វិស័យកសិកម្មនឹងមានកំណើនប្រមាណ ៤,៧% (ក្នុងនោះផលិតផលស្រូវនឹងកើនប្រមាណ ៥,៥% ហើយផលិតផលជលផលនឹងកើនប្រមាណ ២,៥%) វិស័យឧស្សាហកម្មនឹងមានកំណើនប្រមាណ ១០,៧% (ក្នុងនោះផលិតផលវាយនភ័ណ្ឌនឹងកើនប្រមាណ ១២,៣% ហើយផលិតផល សំណង់នឹងកើនប្រមាណ ៩,៨%) និង វិស័យសេវាកម្មនឹងមានកំណើនប្រមាណ ៩,៦% (ក្នុងនោះសកម្មភាពទេសចរណ៍នឹងកើនប្រមាណ ១៣%) ។ អត្រាអតិផរណានឹងនៅតែអាចរក្សាបាននៅក្នុងរង្វង់ ៣,៥% ហើយអត្រាប្តូរប្រាក់នឹងនៅតែរក្សាបានស្ថេរភាពដដែលគឺក្នុងរង្វង់ ៤ ១០០ រៀល ក្នុង ១ ដុល្លាអាមេរិក ។

៤- ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលមធ្យម (២០០៨-២០១០) សេដ្ឋកិច្ចនឹងនៅតែអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% ស្របតាមគោលដៅ **យុទ្ធសាស្ត្រចតុកោណ** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។ តាមការព្យាករណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចជាមធ្យមសំរាប់រយៈពេលមធ្យមពី ឆ្នាំ ២០០៨ ដល់ ២០១០ ខាងមុខ គឺអាចនឹងសំរេចបានប្រមាណ ៧% ដោយសារវិស័យកសិកម្មនឹងកើនជាមធ្យម ៤% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនជាមធ្យមប្រមាណ ៤,៧% វិស័យឧស្សាហកម្មនឹងកើនជាមធ្យម ៨% ដែលក្នុងនោះ ផលិតកម្មវាយនភ័ណ្ឌនឹងកើនជាមធ្យមប្រមាណ ៩% និង ផលិតកម្មសំណង់នឹងកើនជាមធ្យមប្រមាណ ៧,៦% និង វិស័យសេវាកម្មនឹងកើនជាមធ្យម ៨,៤% ដែលក្នុងនោះ សកម្មភាពទេសចរណ៍នឹងកើនជាមធ្យមប្រមាណ ១០% ។ រីឯអត្រាអតិផរណានឹងនៅតែអាចរក្សាបាននៅក្នុងរង្វង់ ៣,៥% ហើយអត្រាប្តូរប្រាក់នឹងអាចរក្សាស្ថេរភាពបានក្នុងរង្វង់ ពី ៤ ១០០ ទៅ ៤២០០ រៀល ក្នុង ១ ដុល្លាអាមេរិក ។

## ខ- *ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ថវិកា*

៥- ការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តន៍គោលនយោបាយរូបិយវត្ថុសមស្រប និង ជាពិសេសការអនុវត្តន៍កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈយ៉ាងមោះមុត គ្រប់ជ្រុងជ្រោយ និង ជាជំហានៗយ៉ាងច្បាស់លាស់ បានធ្វើអោយលទ្ធផលកំណើនសេដ្ឋកិច្ច លទ្ធផលវិស័យហិរញ្ញវត្ថុ និង ធនាគារ ព្រមទាំងលទ្ធផលនៃការអនុវត្តន៍ថវិកាឆ្នាំ ២០០៦ សំរេចបានយ៉ាងល្អប្រសើរគួរជាទីមោទនៈ ។ ជាក់ស្តែង កំណើនសេដ្ឋកិច្ចឆ្នាំ ២០០៦ សំរេចបានរហូតដល់ ១០,៨% ធៀបនឹងការព្យាករណ៍ដើមឆ្នាំ ៦,១% ។ វិស័យហិរញ្ញវត្ថុ

និង ធនាគារបាន និង កំពុងមានការរីកចំរើនគួរអោយកត់សំគាល់ តាមរយៈការរីកដុះដាលនៃធនាគារពាណិជ្ជ ការកើនឡើងនៃប្រាក់បញ្ញើធនាគារ ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធ និង សេវាធនាគារ និង ការពង្រឹងការគ្រប់គ្រងធនាគារ ដែលជាមូលដ្ឋានដ៏សំខាន់សំរាប់ឈានទៅរកការរៀបចំមូលបត្ររដ្ឋ និង មូលបត្រឯកជន និង ការបង្កើតទីផ្សារភាគហ៊ុននៅកម្ពុជា ។

៦- នៅឆ្នាំ ២០០៦ កន្លងទៅនេះ ចំណូលក្នុងស្រុកសរុបសំរេចបាន ១១៦,៩% គឺមានកំនើន ២៤,៧% ធៀបនឹងឆ្នាំ ២០០៥ ហើយស្មើនឹង ១១,៤% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធសំរេចបាន ១១១,៥% ស្មើនឹង ៨,៦% នៃផសស មានកំណើន ២១,៣% ធៀបនឹងឆ្នាំ ២០០៥ និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ៩៨,៣% ស្មើនឹង ២,២% នៃផសស ថយចុះប្រមាណ ៩,៧% ធៀបនឹងឆ្នាំ ២០០៥ ។ រីឯការអនុវត្តន៍ចំណាយវិញក៏មានលក្ខណៈល្អប្រសើរផងដែរ ជាក់ស្តែងចំណាយសរុបឆ្លងកាត់រតនាគារជាតិអនុវត្តបាន ៩៦,៤% មានកំនើន ១៧,១% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ៩,៩% នៃផសស ដែលក្នុងនោះ ចំណាយចរន្តអនុវត្តន៍បាន ៩៩,៤% មានកំណើន ១៨,៨% និង ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេសអនុវត្តន៍បាន ៨២,៤% មានកំណើន ៨,៤% ធៀបនឹង ឆ្នាំ ២០០៥ រីឯចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តបាន ១៥៥,៧% មានកំណើន ១៧,៧% ធៀបនឹង ឆ្នាំ ២០០៥ ។ ទន្ទឹមនឹងនេះ ចំណាយតាមវិស័យដែលអនុវត្តបានគឺ វិស័យរដ្ឋបាលទូទៅសំរេចបាន ១៣១,៥% កើនឡើង ២២,៥% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ១,៥% នៃផសស វិស័យការពារជាតិ និង សន្តិសុខសំរេចបាន ១០៦,៦% កើនឡើង ១៥,៣% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ១,៧% នៃផសស វិស័យសេដ្ឋកិច្ចសំរេចបាន ១០៣,៥% កើនឡើង ៣៤,៩% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ០,៨% នៃផសស និង វិស័យសង្គមកិច្ចសំរេចបាន ១០០% កើនឡើង ២២,៧% ធៀបនឹងឆ្នាំ ២០០៥ ស្មើនឹង ៣% នៃផសស ។ លទ្ធផលនៃការអនុវត្តន៍ចំណូល និង ចំណាយនេះ បានធ្វើអោយមានអតិរេកចរន្តស្មើនឹង ១,៩% និង ឱនភាពថវិកាសរុបស្មើនឹង ៣% នៃផសស ។

៧- ទោះជាកំណើនសេដ្ឋកិច្ចឆ្នាំ ២០០៧ អាចនឹងសំរេចបានរហូតដល់ ៨,៥% ធៀបនឹងការព្យាករណ៍ដើមឆ្នាំត្រឹម ៦,៥% ក៏ដោយ តែកំណើននេះទាបជាងការអនុវត្តន៍បានជាក់ស្តែងក្នុងឆ្នាំ ២០០៦ ដែលមានរហូតដល់ ១០,៨% ។ នេះជាសេណារីយ៉ូប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ជាពិសេស កម្ពុជាអាចនឹងរងឥទ្ធិពលនៃការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និង ចិន និង កត្តាឱនភាពថវិកា និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ។ ទោះជាយ៉ាងណាក៏ដោយ យើងសង្ឃឹមថានឹងមិនមាន ឥទ្ធិពលជាអវិជ្ជមានធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ពិសេស លើការអនុវត្តន៍ថវិកាឡើយ លើកលែងតែមានគ្រោះទឹកជំនន់ ឬ គ្រោះរាំងស្ងួត ដែលអាចនឹងតំរូវអោយមានចំណាយបន្ថែមឥតគ្រោងទុកកើនឡើង ។ ចំណូលក្នុងស្រុកសរុបអាចនឹងសំរេចបាន ១០,៥% នៃផសស ថយចុះប្រមាណ ០,៩% នៃផសស ធៀបនឹងឆ្នាំ ២០០៦ (ដោយសារចំណូលមូលធនក្នុងស្រុកថយចុះគឺចំណូលពីឯកជនភាវូបនីយកម្ម) ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសំរេចបាន ៨,៧% នៃផសស កើនប្រមាណ ០,១% នៃផសស ចំណូលមិនមែនសារពើពន្ធនឹងសំរេចបាន ១,៨% នៃផសស កើនឡើងប្រមាណ ០,២% នៃផសស ធៀបនឹងឆ្នាំ ២០០៦ និង ចំណូលមូលធននឹងសំរេចបានប្រមាណ ៤,៧% នៃផសស ថយចុះប្រមាណ ១,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ។

ចំណាយសរុបអាចនឹងសំរេចបាន ១៤,៥% នៃផសស កើនឡើង ០,២% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះ ចំណាយចរន្តនឹងសំរេចបាន ៨,៧% នៃផសស កើនឡើង ០,៣% នៃផសស ធៀបនឹង ឆ្នាំ ២០០៦ និង ចំណាយមូលធនអាចនឹងសំរេចបាន ៥,៨% នៃផសស ថយចុះប្រមាណ ០,១% នៃ ផសស ធៀបនឹងឆ្នាំ ២០០៦ ។ ការអនុវត្តន៍ចំណូល និង ចំណាយនេះអាចនឹងធ្វើអោយមានអតិរេកចរន្តប្រមាណ ១,៨% នៃផសស និង និនភាពថវិកាសរុបប្រមាណ ៣,៩% នៃផសស ។

៨- ការបន្តពង្រឹង និង បង្កើនសមត្ថភាព និង ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល និង ចំណាយ ក្នុងក្របខ័ណ្ឌ **កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ការអនុវត្តន៍ចំណូល និង ចំណាយឆ្នាំ ២០០៧ សង្ឃឹមថានឹងទទួលបានលទ្ធផលល្អប្រសើរជាងឆ្នាំ ២០០៦ មួយកំរិតបន្ថែមទៀត ។ ជាក់ស្តែង លទ្ធផលនៃការប្រមូលចំណូលត្រីមាសទី១ បានបង្ហាញអោយឃើញថា ចំណូលក្នុងស្រុកសរុបសំរេចបាន ២៥% នៃផែនការឆ្នាំ មានកំណើនប្រមាណ ២% ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះចំណូលគយ និង រដ្ឋាករសំរេចបាន ២៣% មានកំណើន ៣% ធៀបនឹងឆ្នាំ ២០០៦ ពន្ធដារសំរេចបាន ៣០% ស្មើនឹងឆ្នាំ ២០០៦ និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ២២% មានកំណើន ៤% ធៀបនឹងឆ្នាំ ២០០៦ ។ ទោះជាការដាក់អោយអនុវត្តប្លង់គណនេយ្យថ្មី មាតិកាថវិកាថ្មី ព្រមទាំងការកែលំអនិតិវិធីចំណាយ និង លទ្ធកម្មសាធារណៈ បានជះឥទ្ធិពលខ្លះដល់ការចំណាយនៅក្នុងត្រីមាសទី១ ឆ្នាំ ២០០៧ នេះក៏ដោយ ក៏ពុំមានលក្ខណៈធ្ងន់ធ្ងរដែរ ព្រោះចំណាយសរុបឆ្លងកាត់រតនាគារជាតិត្រីមាសទី១ នៅតែសំរេចបានប្រមាណ ១២% នៃផែនការឆ្នាំ គឺទាបជាងតែប្រមាណ ២% ប៉ុណ្ណោះបើធៀបនឹងត្រីមាសទី១ ឆ្នាំ ២០០៦ ហើយចំណាយនៅក្នុងត្រីមាសទី២ នេះ ប្រាកដជានឹងកើនឡើង បន្ទាប់ពីគោលការណ៍ និង នីតិវិធីថ្មីទាំងនោះត្រូវបានអនុវត្តដោយរលូន ។

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ និង ថវិកាឆ្នាំ ២០០៨

### ក. *ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៩- ឆ្នាំ ២០០៨ គឺជាឆ្នាំទី ៣ នៃការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ជាឆ្នាំទី ៤ នៃការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តរក្សាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ពី ៦ ទៅ ៧ ភាគរយ ប្រកបដោយចិរភាព និង បន្តរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និង ចាំបាច់បំផុតក្នុងការឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន*** ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំដែលត្រូវបន្តជំរុញការអនុវត្តន៍កម្មវិធីកែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ដូចជា ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង ជាពិសេសគឺជាឆ្នាំដែលត្រូវរៀបចំការបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

១០- ឆ្នាំ ២០០៨ គឺជាឆ្នាំដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែបន្តវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធ ដើម្បីឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការរីកធំធាត់ជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និង សេវាកម្ម នៅក្នុងរចនាសម្ព័ន្ធផលិតផលក្នុងស្រុកសរុប ។ ប្រការនេះ ទាមទារអោយមានការបន្តពង្រីកមូលដ្ឋាននៃកំណើន តាមរយៈការលើកស្ទួយវិស័យកសិកម្ម និង ការពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ដើម្បីបង្កើនតំលៃបន្ថែមលើផលិតកម្ម និង ស្រូបយកពលកម្មដែលត្រូវបន្តផ្ទេរជាបន្តបន្ទាប់ពីវិស័យកសិកម្ម ។ ធ្វើយ៉ាងនេះ ទើបអាចធានាការបន្តរក្សាបាននូវចិរភាព និង សមធម៌នៃកំណើនសេដ្ឋកិច្ចបាន ។ ដូច្នេះ នៅក្នុងរយៈពេលមធ្យម (២០០៨-២០១០) កំណើនសេដ្ឋកិច្ចកម្ពុជានឹងបន្តកើនឡើង ក៏ប៉ុន្តែនឹងកើនក្នុងល្បឿនមួយយឺតជាងមុន ហើយល្បឿននេះអាស្រ័យដោយល្បឿននៃការបង្កើនផលិតភាពកសិកម្ម និង ការពង្រីក និង ពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ។ ទោះជាយ៉ាងណាក៏ដោយ មូលដ្ឋានសេដ្ឋកិច្ចនឹងនៅតែអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% នៅក្នុងរយៈពេលមធ្យមនេះ ។ តាមការព្យាករណ៍ ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៨ ខាងមុខនេះ អាចនឹងសំរេចបានប្រហែល ៧% ដោយសារវិស័យកសិកម្មនឹងកើនឡើង ៤,១% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនឡើងប្រមាណ ៤,៩% វិស័យឧស្សាហកម្មនឹងកើនឡើង ៨,៣% ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងកើនឡើងប្រមាណ ៨,៨% និង ផលិតផលសំណង់នឹងកើនឡើង ៨,៦% និង វិស័យសេវាកម្មនឹងកើនឡើង ៨,២% ដែលក្នុងនោះ ទេសចរណ៍នឹងកើនឡើងប្រមាណ ១០% ។

## ខ- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា

១១- ដោយផ្អែកលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណ** ជាពិសេស គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ថវិកាឆ្នាំ ២០០៨ មានគោលដៅសំខាន់ៗ ដូចតទៅៈ

- ធានាអោយបាននូវការអនុវត្តន៍គោលនយោបាយអាទិភាពតាមវិស័យ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាល ។
- ធានាការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ដើម្បីរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង បង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។
- ធានាបំពីអោយការបន្តសកម្មភាពកែទំរង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាល លើគ្រប់មុខសញ្ញា ដូចជា កំណែទំរង់រដ្ឋបាលសាធារណៈ កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទំរង់អភិវឌ្ឍន៍វិស័យឯកជន កំណែទំរង់ប្រព័ន្ធច្បាប់ និង តុលាការ កំណែទំរង់វិស័យកងទ័ព កំណែទំរង់ការគ្រប់គ្រងដីធ្លី និង ការពង្រឹងអភិបាលកិច្ចល្អ ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (២០០៨-២០១០)

- ធានាបំពីអោយការរៀបចំបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ។
- ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ និង សុខាភិបាល ។
- ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំពីអោយវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍន៍ជនបទ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ។

១២- ដើម្បីសំរេចបានតាមគោលដៅនៃគោលនយោបាយខាងលើ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តន៍បណ្តាគោលនយោបាយ និង កម្មវិធីកែទំរង់សំខាន់ៗ ដូចខាងក្រោម៖

*ក.* បន្តអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសំរេចអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចីរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប ។

*ខ.* បន្តអនុវត្តកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការឈានទៅសំរេចអោយបាននូវគោលដៅដំណាក់កាលទី១ គឺការធានាភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការបន្តជំរុញការកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និង ធ្វើសមាហរណកម្មថវិកា ដើម្បីធានាអោយការបើកផ្តល់ថវិកាបានទាន់ពេលវេលា និង ការកសាងក្របខ័ណ្ឌគោលនយោបាយចំណូលដើម្បីរក្សាស្ថេរភាព និង និរន្តរភាពចំណូល ។ ទន្ទឹមនឹងនេះ បន្តជំរុញការរៀបចំផែនការសកម្មភាព និង បន្តអនុវត្តន៍នូវបណ្តាសកម្មភាពការងារសំរាប់ត្រៀមឈានទៅដំណាក់កាលទី ២ និង ទី ៣ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និង ការពង្រឹងការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយ ដែលរួមមាន ការបន្តពង្រឹង និង កែលំអការអនុវត្តន៍ប្លង់គណនេយ្យ និង មាតិកាថវិកាថ្មី ការបន្តពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ថវិកាតាមកម្មវិធី និង ការបន្តជំរុញការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីអោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មី ដែលបាន និង កំពុងកសាង និង ដាក់អោយអនុវត្តដោយផ្នែកៗ និង ជាបណ្តើរៗ ក្រោមកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ។

*គ.* បន្តអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ជាពិសេសលើកស្ទួយវិស័យកសិកម្ម និង កសិ-ឧស្សាហកម្ម និង ជួយគាំទ្រសហគ្រាសធុនតូច និង មធ្យម ព្រមទាំងជំរុញការសំរួលពាណិជ្ជកម្មតាមរយៈការបង្កើតបញ្ជរតែមួយ និង ជំរុញផ្នែកឯកជនអោយចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយនឹងមានច្បាប់សម្បទានធានា ក្នុងខណៈដែលរាជរដ្ឋាភិបាលខ្លួនឯងបាន និង កំពុងខិតខំកសាងដោយផ្ទាល់នូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ ប្រការទាំងនេះ ទាមទារការពង្រឹងអភិបាលកិច្ចល្អ ពិសេសវិធានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍កម្មវិធីសកម្មភាពកំណែទំរង់ច្បាប់ និង ប្រព័ន្ធតុលាការ ការពង្រឹងនីតិរដ្ឋ និង ការពង្រឹងវិមជ្ឈការ និង វិសហមជ្ឈការ ។

ឃ. បន្តអនុវត្តនូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីជួយគាំទ្រដល់វិស័យកសិកម្មអោយសមស្រប តាមច្បាប់ភូមិបាល ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំពេញគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ។

ង. បន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀងគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន ។

ច. កសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង លិខិតបទដ្ឋាននានា ជាពិសេសពង្រឹងរចនាសម្ព័ន្ធស្ថាប័ន និង បំពេញភាតព្វកិច្ចកម្ពុជា ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីទាញប្រយោជន៍ពីសមាជិកភាពនេះអោយបានជាអតិបរមា ។

ឆ. បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ពិសេស ធានាពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និង ពង្រីកមូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបម្រើឱ្យគោលការណ៍ «រដ្ឋបាលឯកភាព» ដូចមានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំ និង អនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និង ការផ្តល់ថវិកាជូនមូលនិធិឃុំ-សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបន្តសិក្សាដើម្បីដាក់ឱ្យអនុវត្តសាកល្បងនូវការប្រមូលចំណូលផ្ទាល់ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ជ. បន្តជម្រុញការអនុវត្តន៍កំណែទម្រង់រដ្ឋបាលសាធារណៈ រួមមានការពង្រីកការអនុវត្តន៍កន្សោមអាទិភាព ជាពិសេស កម្មវិធីផ្តល់លាភការទៅតាមសមត្ថភាព និង លទ្ធផលការងារ និង ការវិភាគមុខងារ ដើម្បីបង្កើនផលិតភាព និង ប្រសិទ្ធភាពការងារ ។

## III. ការគណនា និង ទិសដៅនៃថវិកាឆ្នាំ ២០០៨

### ក- គំរោងចំណាយថវិកា

១៣- ដើម្បីធានាបាននូវការអនុវត្តន៍ទៅតាមគោលដៅទាំងអស់ខាងលើ និង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០០៨ ត្រូវគ្រោងលើមូលដ្ឋានយុទ្ធសាស្ត្រ និង វិធានការដូចខាងក្រោម៖

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ និង ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកំរិត ១៥,៤% នៃផសស គឺកើនឡើងប្រមាណ ១% នៃផសស ដែលក្នុងនោះ ចំណាយចរន្តសរុបនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ៩,៧% នៃផសស និង ចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៥,៧% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,២% នៃផសស និង ឱនភាពថវិកាសរុបក្នុងរង្វង់ ៤,៣% នៃផសស ។ ដោយឡែក ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ១,១% នៃផសស ហើយចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៤,៣% នៃផសស ។ ទន្ទឹមនឹងនេះ ចំណាយសំគប់រំលស់

ចំណុលត្រូវកំណត់ត្រឹម ០,៣% នៃផសស ។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលនឹងបន្តគោលនយោបាយឧបត្ថម្ភថ្លៃអគ្គិសនីដល់អ្នកប្រើប្រាស់ ជាពិសេស ចំពោះអ្នកក្រីក្រ តាមរយៈការចេញពន្ធលើតំលៃបន្ថែមជំនួសអគ្គិសនីកម្ពុជា ។

• ត្រូវវិភាជន៍ចំណាយចរន្តទៅតាមវិស័យនីមួយៗដូចតទៅៈ វិស័យសង្គមកិច្ចស្មើនឹង ៣,៤% នៃផសស មានកំណើន ១៧% ធៀបនឹងឆ្នាំ ២០០៧ វិស័យសេដ្ឋកិច្ច ០,៨% នៃផសស មានកំណើន ២០% ធៀបនឹងឆ្នាំ ២០០៧ វិស័យរដ្ឋបាលទូទៅ ១,៣% នៃផសស មានកំណើន ១៤% ធៀបនឹងឆ្នាំ ២០០៧ វិស័យការពារជាតិ និង សន្តិសុខ ១,៥% នៃផសស មានកំណើន ១០% ធៀបនឹងឆ្នាំ ២០០៧ និង ថវិកាផ្ទាល់របស់ខេត្ត-ក្រុងប្រមាណ ០,៥% នៃផសស មានកំណើន ៦០% ធៀបនឹងឆ្នាំ ២០០៧ ។

១៤- ថវិកាឆ្នាំ ២០០៨ ខាងមុខនេះ ត្រូវបំរើគោលនយោបាយរាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច និង ការលើកស្ទួយជីវភាពនៅទីជនបទ សំដៅសំរេចនូវការអភិវឌ្ឍន៍ប្រកបដោយចិរភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០០៨ ត្រូវផ្តល់ការវិភាជន៍ជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗដូចខាងក្រោម៖

• បន្តបង្កើនថវិកាសំរាប់វិស័យអប់រំ និង សុខាភិបាលអោយស្របទៅតាមគោលដៅនៃកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យអប់រំ និង សុខាភិបាលឆ្នាំ ២០០៨-២០១០ ។

• បន្តបង្កើនថវិកាសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធរបរន្ត ការអភិវឌ្ឍន៍កសិកម្ម និង ការអភិវឌ្ឍន៍ជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ចដើម្បីកំណើន សមធម៌ និង ការកាត់បន្ថយភាពក្រីក្រ ។

• បង្កើនមូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ ២០០៨ ដល់ ២,៧% នៃចំណូលចរន្តថវិកាជាតិឆ្នាំ ២០០៧ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ស្របតាមគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ។

• បន្តផ្តល់អាទិភាពនៃការវិភាជន៍ថវិកាដល់ថវិកាតាមកម្មវិធី និង ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានបញ្ជាក់ពីគោលបំណង ទិសដៅគោលនយោបាយ កម្មវិធី និង/ឬ យុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និង សូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តន៍គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និង បង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ការបន្តពង្រឹង និង ការកែលំអការរៀបចំ និង ការអនុវត្តន៍ថវិកាតាមកម្មវិធី ។

**ខ- គំរោងចំណូលថវិកា**

១៥- ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃគំរោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និង ការអនុវត្តន៍អោយបានសំរេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសំរេចអោយបាននូវកំរិតចំណូលក្នុងស្រុកសរុបប្រមាណ ១១% នៃផសស គឺមានកំណើន ០,៥% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ដែលក្នុងនោះ ចំណូលសារពើពន្ធ

ត្រូវសំរេចអោយបាន ៩,១% នៃផសស គឺមានកំណើន ០,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ចំណូលមិនមែនសារពើពន្ធត្រូវសំរេចអោយបាន ១,៧% នៃផសស ស្មើនឹងឆ្នាំ ២០០៧ និង ចំណូលមូលធនក្នុងស្រុកត្រូវសំរេចអោយបាន ០,៣% នៃផសស គឺមានកំណើន ០,២% ធៀបនឹងឆ្នាំ ២០០៧ ។

១៦- ដើម្បីសំរេចបានតាមគោលដៅនៃការប្រមូលចំណូលសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តអនុវត្តសកម្មភាពការងារ និង បណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតទៅលើបណ្តាវិធានការសំខាន់ៗមួយចំនួនដូចខាងក្រោម ÷

**ទី១- ផ្នែកចំណូលពន្ធដារ:**

- បន្តពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និង ការធ្វើចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។
- បន្តពង្រឹងការអនុវត្តន៍កម្មវិធីកែលំអរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តន៍តួនាទី ភារកិច្ច និង ប្រតិបត្តិការរបស់នាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃនាយកដ្ឋានពន្ធដារ ។
- បន្តបញ្ចប់ការកសាង និង ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាពត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។
- បន្តពង្រឹងការអនុវត្តន៍អោយបានគ្រប់ជ្រុងជ្រោយ និង ឱ្យបានហ្មត់ចត់នូវរាល់បទបញ្ញត្តិទាំងឡាយ នៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។
- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និង ពង្រឹងការអនុវត្តន៍របបពិតនៅតាមបណ្តា ខេត្ត- ក្រុង និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។
- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និង មធ្យម ។
- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និង ឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និង ឧស្ម័ន ។
- បន្តធ្វើការសិក្សាអំពីចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។
- បន្តពង្រឹងអភិបាលកិច្ចរបស់នាយកដ្ឋានពន្ធដារ ។

**ទី២- ផ្នែកចំណូលពន្ធគយ:**

- ជំរុញការអនុម័តសេចក្តីព្រាងច្បាប់គយ និង ត្រៀមរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋានដើម្បីជំរុញការអនុវត្តន៍ច្បាប់នេះ ។

- បន្តកែលំអនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ- ចូល និង ក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីបាននូវតម្លាភាព និង ភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។

- បន្តរៀបចំកែលំអ និងដាក់អោយអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់ទីចាត់ការគយ និងរដ្ឋាករ ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមានៈ

*ក. បន្តពង្រឹងការអនុវត្តន៍បណ្តាវិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ* ដោយសហការយ៉ាងជិតស្និទជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និង អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តន៍ការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និង ប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលំអផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិទភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូនបរិក្ខារ អេឡិចត្រូនិច និង ការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ. បន្តពង្រឹងការសហការជាមួយនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរពត៌មាន* រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។

*គ. បន្តរិះរក និង ដាក់អោយអនុវត្តនូវវិធានការច្បាស់លាស់ និង ទន់ភ្លន់* លើមុខទំនិញមួយចំនួនដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិៈ បន្តការបណ្តុះ-បណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តពង្រឹង និង កែលំអរដ្ឋបាលគយ តាមរយៈការជំរុញអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និង យន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជន ។

- បន្តពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាឯច្រកកាត់ការបញ្ចូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និង ការប្រមូលចំណូល ។

- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និង រដ្ឋាករ ។

**ទី៣- ផ្នែកចំណូលមិនមែនសារពើពន្ធៈ**

- បន្តជំរុញការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រី លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- បន្តស្រាវជ្រាវ និង កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្ត ជំរុញការអនុវត្តន៍នូវផែនការសកម្មភាព និង បណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះតាមគ្រប់ មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូល

ពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរណ៍ស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការប្រមូលចំណូល។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតំរូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

១៧- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ជាមួយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៧ ។ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីអោយបាននៅក្នុងសប្តាហ៍ទី១ នៃ ខែតុលា ឆ្នាំ ២០០៧ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ហើយផ្ញើជូនរដ្ឋសភាអោយបានក្នុងសប្តាហ៍ទី១ នៃ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដើម្បីស្ថាប័ននីតិបញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ ពិភាក្សា និង អនុម័តសេចក្តីព្រាងច្បាប់នេះអោយបានមុនថ្ងៃ ២៥ ខែធ្នូ ២០០៧ ។

**គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨**

១៨- ទោះជាត្រូវបាន និង កំពុងតែធ្វើអោយប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ លើការគ្រប់គ្រងចំណូល និង ចំណាយ តាមរយៈការអនុវត្តន៍កម្មវិធីកែទំរង់ការគ្រប់គងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈកាលពីរឆ្នាំកន្លងទៅក៏ដោយ រាជរដ្ឋាភិបាលនៅតែបន្តប្រឈមមុខនឹងបញ្ហាមួយចំនួន ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូល ដើម្បីសងបំណុលចាស់ផង និង ដើម្បីបំពេញតម្រូវការចំណាយ ដែលចេះតែកើនឡើងជាលំដាប់ផង ដែលរួមមានដូចជា៖

ទី១- ការបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា អោយបានសមស្របដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ហើយពង្រឹងការរៀបចំថវិកាអោយបានគ្រប់ជ្រុងជ្រោយ និង សុក្រឹត ដើម្បីកាត់បន្ថយជាអតិបរិមានូវចំណាយមិនបានគ្រោងទុក និង សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និង ចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយប្រសិទ្ធភាព និង ប្រកបដោយភាពជឿទុកចិត្តបាន ។

*ទី២-* ការបន្តជំរុញការរៀបចំកម្មវិធីចំណូល- ចំណាយអោយបានសុក្រឹត និង ការអនុវត្តន៍អោយបានហ្មឺងម៉ាត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីកាត់បន្ថយបំណុលសាច់ប្រាក់កកស្ទះនៅរតនាគារ ក្នុងគោលដៅបង្កើនភាពជឿទុកចិត្តបាននៃការអនុវត្តន៍ថវិកា ។ លើសពីនេះ ការបង្កើនការគោរពយ៉ាងហ្មឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេស ចៀសវាងនូវការផ្ទេរឥណទានថវិកាដែលនៅសល់ទៅឆ្នាំបន្ទាប់ ព្រមទាំងការចេញអាណត្តិបម្រុងទុក និង ការចេញអាណត្តិច្រើនហួសទៅបង្គរនៅរតនាគារជាតិដែលជាប្រការធ្វើឱ្យកើតមានឡើងនូវបំណុលសាច់ប្រាក់ថ្មីទៀត ។

*ទី៣-* បន្តពង្រឹងការគ្រប់គ្រងបំណុល ជាពិសេស ការកសាងទិន្នន័យ និង ការរៀបចំកម្មវិធីសងបំណុលអោយបានច្បាស់លាស់ និង ដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និង ការបន្តអនុវត្តយ៉ាងហ្មឺងម៉ាត់នូវការខ្ចីតែឥណទានដែលបំរើអោយគោលនយោបាយអាទិភាព ។

*ទី៤-* បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ជាពិសេស ចំពោះគោលនយោបាយអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានផ្លូវថ្នល់ ស្ពាន និង ប្រព័ន្ធស្រោចស្រព ដែលជាគោលបំណងនៃគោលនយោបាយ និង ជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ។

## III- និតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៨

### ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០០៨

*១៩-* ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
    - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
    - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
    - ការប៉ាន់ស្មានលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
    - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
    - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និង កែលំអរដ្ឋបាល និង គោលនយោបាយពន្ធដារ គយ និង រដ្ឋាករ ការធ្វើវិចារណៈកម្មសារពើពន្ធ និង ការប្រមូលបំណុលពន្ធដែលត្រូវទារ ។

• ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាជួលសេវាកម្ម ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិដែលសំរេចបាននៅក្នុងឆ្នាំកន្លងមក និងការ-អភិវឌ្ឍន៍សេដ្ឋកិច្ច ។ ***គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ទាំងអស់ ត្រូវរៀបចំគំរោងចំណូលនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយបានត្រឹមថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧*** ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ត្រូវរៀបចំកិច្ចប្រជុំពិភាក្សាកំរិតជំនាញលើគំរោងចំណូលនេះជា មួយគ្រប់ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត-ក្រុង និង ធ្វើការបូកសរុបអោយបានចប់សព្វគ្រប់មុនការចាប់ផ្តើមចរចាថវិកានៅដើមខែសីហា ។

**ខ- ការគ្រោងចំណាយថវិកាឆ្នាំ ២០០៨**

២០- ការរៀបចំគំរោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីគណនាតំរូវការថវិកាដោយលំអិតទៅតាម ជំពូក គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើតំរូវការជាក់ស្តែង និង ដោយផ្ទាល់ សំរាប់បំពេញអោយការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាឥណទានចំណាយ ត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈនៃការផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬ សេចក្តីណែនាំ ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សា សំរាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តំរូវការចំណាយនីមួយៗត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និង មានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាមជំពូក គណនី និង អនុគណនីនីមួយៗ ។

**គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៨**

២១- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការណ៍ចំណាយទៅតាមប្រភេទ និង ជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា សំរាប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ធ្វើជាមូលដ្ឋានក្នុងការរៀបចំគំរោងចំណាយលំអិតទៅតាម គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ដើម្បីបំពេញអោយតំរូវការជាក់ស្តែងក្នុងការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃត្រីមាសទី ១ ឆ្នាំ ២០០៨ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ នៅតាមខេត្ត-ក្រុងទេ ។

២២- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និង បណ្តាវិធានការដូចខាងក្រោម៖

ក- ចំណាយបន្ទុកបុគ្គលិក ត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៧ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និង តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណៈភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង មិនត្រូវគិតអតិផរណានៅក្នុងចំណាយបៀវត្សនេះទេ ។ ចំពោះ បុគ្គលិកអណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានា ចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង - ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។

ខ- ចំណាយដំណើរការលើការទិញ និង សេវា ត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និង សន្សំសំចៃបំផុត ជាពិសេស ចំពោះសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវ មិនត្រូវបង្កើនចំណាយលើសពីឆ្នាំកំពុងអនុវត្តទេ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនអោយមានចំណាយលើសពីឥណទានថវិកាដែលបានគ្រោងសំរាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬ សេវាមកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។ កន្លងមកចំណាយសំរាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវមានលក្ខណៈខ្វះខ្វាយ ។ ចំណាយសំរាប់មុខសញ្ញាទាំងនេះចេះតែកើនឡើង ហើយការទូទាត់មិនបានទាន់ពេលវេលាដែលនាំអោយមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយអគ្គិសនី ទូរស័ព្ទ និង ទឹក ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និង ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក អោយបានត្រឹមត្រូវ ម៉ត់ចត់ និង ប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្លំចរន្តអគ្គិសនី ទូរស័ព្ទ និង ទឹក ប្រើបាស់ផ្ទាល់ខ្លួនខុសមុខសញ្ញា របស់ក្រសួង ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និង ចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសំរាប់អគ្គិសនី ទូរស័ព្ទ និង ទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុនធ្វើជាពិដាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះអោយចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ពិតប្រាកដរបស់ក្រសួងស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក័យប័ត្រប្រចាំខែនីមួយៗ អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ក្រសួង- ស្ថាប័ន និង

មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក័យប័ត្រ និង រៀបចំទូទាត់អោយបានទៀងទាត់ និង ទាន់ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនអោយមានការពន្យាការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការមទេ ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ហើយដាក់ឱ្យគ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និង ហ្មឹងម៉ាត់បំផុត ។

ត- ចំពោះចំណាយសំរាប់ជំពូក គណនី និង អនុគណនីផ្សេងៗទៀត ត្រូវគ្រោងទៅតាមតំរូវការ ចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ក្នុងករណី តំរូវអោយមានកំណើន ដោយមានការវិភាគ និង ពន្យល់ច្បាស់លាស់ ក៏កំណើននោះមិនត្រូវអោយលើសពី ៣% នៃកញ្ចប់ថវិកាដែលបានអនុម័តឆ្នាំ ២០០៧ ដែរ ។ ចំពោះក្រសួងដែលត្រូវបន្ត ឬ ចាប់ផ្តើមអនុវត្ត សាកល្បងថវិកាតាមកម្មវិធី ត្រូវញែកគំរោងចំណាយជាពីរផ្នែកសំរាប់ថវិកាតាមកម្មវិធី និង ថវិកាតាមមាតិកា ទៅតាមគ្រប់ជំពូក គណនី និង អនុគណនីនីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំង នេះមកការពារគំរោងថវិកាតាមកម្មវិធីដោយឡែក ។

ឃ- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គំរោងចំណូល និង គំរោងចំណាយថវិកា ដែលក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាមូលដ្ឋានសំរាប់ការពិភាក្សា នៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬ មន្ទីរជំនាញខេត្ត- ក្រុង ដែលមិនបានបំពេញ និង ផ្តល់ពត៌មានគ្រប់គ្រាន់សំរាប់ការប្រជុំការពារថវិកាទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវជូនពត៌មានទៅអង្គភាពអោយបានទាន់ពេលវេលា ដើម្បីបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការ យកមូលដ្ឋាននៃថវិកាឆ្នាំ ២០០៧ ហើយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូក គណនី និង អនុគណនីខាង លើ សំរាប់កំណត់គំរោងថវិការបស់អង្គភាពនោះ ដើម្បីជាមូលដ្ឋានសំរាប់ការប្រជុំការពារថវិកា និង រៀបចំ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអោយបានទាន់ពេលវេលា ។

**ឃ- ការរៀបចំ និង ការវិភាគសំណើនានា**

២៣- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (ក-1) ឆ្នាំ ២០០៧ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៦ /០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០៨ ឆ្នាំ (ក) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការ ទៅបាន ។ ក្រសួង- ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និង ការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតំរូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុ ដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា៖
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែង ចែកឥណទានដើមនៃក្រសួង- ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត- ក្រុងមានការប្រែប្រួល ។

- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ ល ។

២៤- គំរោងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៥- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៦- បច្ចេកទេសវិភាគដ៏ទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងនីមួយៗ ត្រូវតែបំពីទៅលើ៖

- គោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ក្រសួង- ស្ថាប័ន និង មន្ទីរ ជំនាញខេត្ត- ក្រុងនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា
- កម្មវិធី និង យុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសំរេចបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន
- ផែនការសកម្មភាព និង រាល់មធ្យោបាយដំណើការ ដើម្បីអនុវត្តកម្មវិធី និង យុទ្ធសាស្ត្រអាទិភាព
- ការគ្រប់គ្រង ការតាមដាន ការវាយតំលៃ និង ការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តន៍កម្មវិធី និង យុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសំរាប់សំរេចបានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។

## IV- សេចក្តីសន្និដ្ឋាន

២៧- ដើម្បីសំរេចបានតាមគោលដៅ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ជាពិសេស ការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង កំណើនខ្ពស់ជាមធ្យម ពី ៦ ទៅ ៧ ភាគរយ ប្រកបដោយចិរភាពគឺជាធនធានចាំបាច់ និង មិនអាចខ្វះបាន ។ ដើម្បីអោយធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ នោះគឺ ទាមទារអោយគ្រប់ក្រសួង- ស្ថាប័នទាំងអស់

ត្រូវមានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួនយ៉ាងច្បាស់លាស់ ដែលផ្សារភ្ជាប់ទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** មានកម្មវិធី និង យុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវក្នុងការអនុវត្តន៍ឆ្ពោះទៅសំរេចអោយបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកំពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ជាពិសេស ការកែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

២៨- ពេលទទួលសារាចរណែនាំនេះ *គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់នូវតារាងចំណូល-ចំណាយថវិការបស់ខ្លួន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរ បំផុតត្រឹមថ្ងៃទី* ***១៣*** *ខែកក្កដា ឆ្នាំ* ***២០០៧*** ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ការពិភាក្សាកិរិតជំនាញ និង បូកសរុបសំរាប់ការចរចាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែសីហា ឆ្នាំ ២០០៧ ។ តួរលេខតារាងចំណូល-ចំណាយ ថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

២៩- ក្នុងការអនុវត្តន៍សារាចរណែនាំនេះ បើក្រសួង-ស្ថាប័ន និង មន្ទីជំនាញខេត្ត-ក្រុងមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

***"ដើម្បីជូនជ្រាប"***

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

***"ដើម្បីអនុវត្ត"***

- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ [illegible] សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មិថុនា ឆ្នាំ ២០០៧

**សូមគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**កម្មវត្ថុៈ សំណើសុំពិនិត្យសំរេចលើសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨**

**យោងៈ** - ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ ថ្មី នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦ /០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ។
- សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៨ ចុះថ្ងៃទី ១៣ មេសា ឆ្នាំ ២០០៧ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបសម្តេចនាយករដ្ឋមន្ត្រីមេត្តាជ្រាបថាៈ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ អោយបានទាន់ពេលកំណត់ ជាពិសេស ដើម្បីអោយក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ មានពេលវេលាគ្រប់គ្រាន់សំរាប់រៀបចំគំរោងចំណូល- ចំណាយរបស់ខ្លួន ប្រកបដោយសុក្រឹតភាព និង ប្រសិទ្ធភាព មាត្រា ២៦ ថ្មី នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ តំរូវអោយចេញសារាចរណែនាំនេះនៅក្នុងសប្តាហ៍ទី១ នៃខែ មិថុនា ។

អាស្រ័យហេតុនេះ សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាពិនិត្យសំរេច និង ចុះហត្ថលេខាដ៏ខ្ពង់ខ្ពស់លើសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ដូចមានជូនភ្ជាប់មកជាមួយនេះ ដើម្បីអោយក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានមូលដ្ឋានក្នុងការចាប់ផ្តើមរៀបចំគំរោងចំណូល- ចំណាយ ហើយចរចារ និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ អោយបានទាន់ពេលវេលា ។

សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់ខ្ញុំ

[illegible]
8-6-07

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**